ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D338/1/1/3

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៨)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ជាប្រធាន**
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ី ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: **ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧**

សាធារណៈ: កោសលុប

សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ

សហព្រះរាជអាជ្ញា:

ជា លាង
Nicholas KOUMJIAN

សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:

សូ មូស្សេទ្ធី
Susana TOMANOVIĆ
Neville SORAB

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់ [redacted] ទៅក្នុងអំពើព្រហ្មទណ្ឌ និងស្នើសុំឱ្យចោទប្រកាន់មកលើរូបគាត់[2]។ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយស្នើសុំ ក.ស.ច.ស ឱ្យដាក់របាយការណ៍វិភាគដែលរៀបចំដោយ [redacted] ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មក្រាំងតាចាន់ និងវត្តប្រធាតុ ទៅក្នុងសំណុំរឿង ០០៤ ("សំណើ")[3]។ នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៧ និងថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានជូនដំណឹងអំពីដីកាសម្រេចរបស់គាត់បដិសេធសំណើ ជាសំណៅភាសាអង់គ្លេស និងភាសាខ្មែរ ("ដីកាសម្រេចដែលរងការជំទាស់")[4]។ ស.ព.អ បានដាក់សេចក្តីជូនដំណឹងរបស់គាត់ស្តីពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ ("សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍")[5] និងបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៤ ខែ កក្កដា

---

[1] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D338/1/1/1។

[2] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ ឯកសារ D338 កថាខណ្ឌ ១។

[4] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D338/1។

[5] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D338/1/1។

ឆ្នាំ ២០១៧។ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧ សហមេធាវីការពារក្តី [redacted] ("មេធាវីការពារក្តី") បានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ("ចម្លើយតប")[6]។ ស.ព.អ ពុំបានដាក់ការឆ្លើយតបទេ។

II. ភាពឧទ្ធលយកបាន

ក. សារណា

2. ស.ព.អ លើកឡើងថា បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ "អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង"[7]។ នៅក្នុងចម្លើយតប មេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះឱ្យសន្និដ្ឋានថាមិនអាចទទួលយកបាន[8] ដោយសារ "វាត្រូវបានដាក់ក្នុងរយៈពេលប្រាំបួនថ្ងៃ បន្ទាប់ពីរយៈពេលដែលបានកំណត់ដោយ វិធាន ៧៥(៣) [នៃវិធានផ្ទៃក្នុង] ដែលបានផុតកំណត់នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧"[9] ហើយ "ស.ព.អ មិនបានស្នើសុំពន្យារពេល"[10]។

ខ. ការពិភាក្សា

3. វិធាន ៧៥(១) និង (៣) តម្រូវថា៖

> "១. លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ *គ្រប់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងក្នុងអំឡុងពេល ១០(ដប់)ថ្ងៃ* គិតចាប់ពីថ្ងៃ*ដែលទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា។* [...]
>
> ៣. ការដាក់សារណា*បណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃបានទទួលសេចក្តី*

---

[6] ចម្លើយតបរបស់ [redacted] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D338/1/1/2។

[7] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១។

[8] ចម្លើយតប ទំព័រ ៥។

[9] ចម្លើយតប កថាខណ្ឌ ៩។

[10] *ដូចយោងខាងលើ*។

01522637

ជូនដំណឹង អំពីសេចក្តីសម្រេច ឬដីកា។ ក្នុង*កាលៈទេសៈពិសេស* រយៈពេលកំណត់នេះ *អាចពន្យារបាន*"។

4. ជាងនេះទៀត អនុលោមតាមវិធាន ៣៩(១) និង (៤) នៃវិធានផ្ទៃក្នុង៖

"១. *គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងច្បាប់ជាធរមាន* វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង សេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្របណាមួយ *ត្រូវតែគោរព*។ ក្នុងករណីនេះ *ការមិនបានគោរពតាមកាលកំណត់ គឺនាំឱ្យកិច្ចដែលបានធ្វើនោះត្រូវចាត់ទុកជាអសុពលភាព*។ [...]

៤. តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាច*៖

ក- ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់។ ឬ

ខ- *ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់* ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ *ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល*"។

5. នៅក្នុងសំណុំរឿងនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចដែលរងការជំទាស់ត្រូវបានជូនដំណឹងទៅភាគីជាភាសាខ្មែរនៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៧ ហេតុនេះ ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ ស្របទៅនឹងពេលវេលាដែលបានកំណត់នៅក្នុងវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណាក្តី ការដាក់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ត្រូវបានធ្វើក្នុងរយៈពេលប្រាំបួនថ្ងៃ បន្ទាប់ពីរយៈពេល ៣០ ថ្ងៃដែលបានកំណត់ដោយវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ដែលនាំឱ្យការដាក់បណ្តឹងឧទ្ធរណ៍មិនមានសុពលភាព អនុលោមតាមវិធាន ៣៩(១) នៃវិធានផ្ទៃក្នុង។

6. អង្គបុរេជំនុំជម្រះពិចារណាឃើញថា នៅក្នុងករណីនេះ ពុំមានការបង្ហាញនូវសំអាងហេតុឱ្យបានត្រឹមត្រូវដើម្បីធ្វើយុត្តិកម្មដល់ទទួលយកបណ្តឹងឧទ្ធរណ៍ដែលបានដាក់ហួសពេលកំណត់នោះទេ។ ស.ព.អ មិនបានដាក់សំណើសុំពន្យារពេល ហើយក៏មិនបានឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីនោះទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះមិនអាចចាត់ទុកជាសំអាងហេតុសមហេតុ

ផលដែលមិនត្រូវគោរពតាមរយៈពេលដែលបានកំណត់នៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងនោះឡើយ[11]។

7. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖

បដិសេធបណ្ដឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧

ប្រធាន **អង្គបុរេជំនុំជម្រះ**

ប្រាក់ គិមសាន **Olivier BEAUVALLET** **ន៉ីយ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

[11] *សូមមើលផងដែរ* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣២) សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត អំពីការបកស្រាយលើ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបនោះ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D191/18/1/8 កថាខណ្ឌ ១៤។